**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**ក្រសួងសុខាភិបាល**

លេខ ០៦០ សខ៦ល

# សេចក្តីសម្រេច

## ស្តីពី

## ការបង្កើតអនុគណៈកម្មការគ្រប់គ្រងសន្តិសុខ និងសណ្តាប់ធ្នាប់នៅតាមគោលដៅ និងតំបន់ចត្តាឡីស័កដើម្បីប្រយុទ្ធនឹងជំងឺកូវីដ-១៩ (COVID-19)

## រដ្ឋមន្ត្រីក្រសួងសុខាភិបាល និងជា ប្រធានគណៈកម្មការអន្តរក្រសួងដើម្បីប្រយុទ្ធនឹងជំងឺកូវីដ-១៩ (COVID-19)

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៨/៩២៥ ចុះថ្ងៃទី០៦ ខែកញ្ញា ឆ្នាំ២០១៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦១៨/០១២ ចុះថ្ងៃទី២៨ ខែមិថុនា ឆ្នាំ២០១៨ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/០៦ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងសុខាភិបាល
- បានឃើញអនុក្រឹត្យលេខ ៦៧ អនក្រ.បក ចុះថ្ងៃទី២២ ខែតុលា ឆ្នាំ១៩៩៧ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួងសុខាភិបាល
- បានឃើញអនុក្រឹត្យលេខ ១២៩ អនក្រ.បក ចុះថ្ងៃទី១៧ ខែកញ្ញា ឆ្នាំ២០១៥ ស្តីពីវិធានការសុខាភិបាលដើម្បីទប់ស្កាត់ និងឆ្លើយតបការឆ្លងរាលដាលជាអន្តរជាតិនៃជំងឺនៅតាមច្រកចេញចូល
- បានឃើញអនុក្រឹត្យលេខ ២៨ អនក្រ.បក ចុះថ្ងៃទី១៨ ខែកុម្ភៈ ឆ្នាំ២០២១ ស្តីពីការកែសម្រួលមាត្រា៨ នៃអនុក្រឹត្យលេខ ១២៩ អនក្រ.បក ចុះថ្ងៃទី១៧ ខែកញ្ញា ឆ្នាំ២០១៥ ស្តីពីវិធានការសុខាភិបាលដើម្បីទប់ស្កាត់ និងឆ្លើយតបការឆ្លងរាលដាលជាអន្តរជាតិនៃជំងឺនៅតាមច្រកចេញចូល
- បានឃើញអនុក្រឹត្យលេខ ២៧ អនក្រ.បក ចុះថ្ងៃទី១៨ ខែកុម្ភៈ ឆ្នាំ២០២១ ស្តីពីវិធានការចត្តាឡីស័កដើម្បីទប់ស្កាត់ការឆ្លងរាលដាលនៃជំងឺកូវីដ-១៩
- បានឃើញសេចក្តីសម្រេចលេខ ២៩ សសរ ចុះថ្ងៃទី១៨ ខែមីនា ឆ្នាំ២០២០ ស្តីពីការបង្កើតគណៈកម្មការជាតិប្រយុទ្ធនឹងជំងឺកូវីដ-១៩ (COVID-19)
- បានឃើញសេចក្តីសម្រេចលេខ ២៦ សសរ ចុះថ្ងៃទី១០ ខែមីនា ឆ្នាំ២០២០ ស្តីពីការបង្កើតគណៈកម្មការអន្តរក្រសួងដើម្បីប្រយុទ្ធនឹងជំងឺកូវីដ-១៩ (COVID-19)

- បានឃើញសេចក្តីសម្រេចលេខ ៣៤ សសរ ចុះថ្ងៃទី២ ខែមេសា ឆ្នាំ២០២០ ស្តីពីការតែងតាំងសមាសភាពគណៈកម្មការអន្តរក្រសួងដើម្បីប្រយុទ្ធនឹងជំងឺកូវីដ-១៩ (COVID-19)
- យោងតាមតម្រូវការចាំបាច់របស់គណៈកម្មការអន្តរក្រសួងដើម្បីប្រយុទ្ធនឹងជំងឺកូវីដ-១៩ (COVID-19)

**សម្រេច**

**ប្រការ១._**

ត្រូវបានបង្កើតអនុគណៈកម្មការគ្រប់គ្រងសន្តិសុខ និងសណ្តាប់ធ្នាប់នៅតាមគោលដៅ និងតំបន់ចត្តាឡីស័ក ដើម្បីប្រយុទ្ធនឹងជំងឺកូវីដ-១៩ (COVID-19) ដែលមានសមាសភាពដូចខាងក្រោម៖

| | |
|---|---|
| ១. ឯកឧត្តម ឧត្តមសេនីយ៍ឯក **ហ៊ុន ម៉ាណែត** អគ្គមេបញ្ជាការរង នៃកងយោធពលខេមរភូមិន្ទ មេបញ្ជាការកងទ័ពជើងគោក និងជាអនុប្រធានគណៈកម្មការអន្តរក្រសួងដើម្បីប្រយុទ្ធនឹងជំងឺកូវីដ-១៩ | ប្រធាន |
| ២. ឯកឧត្តម នាយឧត្តមសេនីយ៍ **គីម ប៊ុនថាន** អគ្គមេបញ្ជាការរង នៃកងយោធពលខេមរភូមិន្ទ | អនុប្រធានអចិន្ត្រៃយ៍ |
| ៣. ឯកឧត្តម នាយឧត្តមសេនីយ៍ **កែម ចណ្ណថន** អគ្គនាយករង នៃអគ្គនាយកដ្ឋានអន្តោប្រវេសន៍ | អនុប្រធាន |
| ៤. ឯកឧត្តម ឧត្តមសេនីយ៍ឯក **ឡោ សុខឡេខ** អគ្គស្នងការរង នៃអគ្គស្នងការដ្ឋាននគរបាលជាតិ | អនុប្រធាន |
| ៥. ឯកឧត្តម **ហ៊ុន ចំរើន** រដ្ឋលេខាធិការក្រសួងសុខាភិបាល | អនុប្រធាន |
| ៦. ឯកឧត្តម **ចាន់ សុធី** រដ្ឋលេខាធិការក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ | អនុប្រធាន |
| ៧. ឯកឧត្តម ឧត្តមសេនីយ៍ឯក **ខឹមដា សារឿន** មេបញ្ជាការរង និងជានាយសេនាធិការបញ្ជាការដ្ឋានកងទ័ពជើងគោក | សមាជិក |
| ៨. ឯកឧត្តម ឧត្តមសេនីយ៍ឯក **ម៉ន សារ៉ុន** មេបញ្ជាការរង បញ្ជាការដ្ឋានកងរាជអាវុធហត្ថលើផ្ទៃប្រទេស | សមាជិក |
| ៩. ឯកឧត្តម **ខួន ផារ័ត្ន** អភិបាលរងនៃគណៈអភិបាលរាជធានីភ្នំពេញ | សមាជិក |
| ១០. ឯកឧត្តម **ម៉ាង ស៊ីណេត** អភិបាលរងនៃគណៈអភិបាលខេត្តព្រះសីហនុ | សមាជិក |
| ១១. ឯកឧត្តម **គិន ប្រាកដ** អភិបាលរងនៃគណៈអភិបាលខេត្តសៀមរាប | សមាជិក |
| ១២. ឯកឧត្តម **លីម សុខគុ** អភិបាលរងនៃគណៈអភិបាលខេត្តឧត្តរមានជ័យ | សមាជិក |
| ១៣. ឯកឧត្តម **ខ៉ោ ម៉េងជ្រួញ** អភិបាលរងនៃគណៈអភិបាលខេត្តបន្ទាយមានជ័យ | សមាជិក |
| ១៤. ឯកឧត្តម **ណុម តារា** អភិបាលរងនៃគណៈអភិបាលខេត្តបាត់ដំបង | សមាជិក។ |

**ប្រការ២._**

អនុគណៈកម្មការនេះមានតួនាទី និងភារកិច្ចក្នុងការគ្រប់គ្រងគោលដៅ និងតំបន់ចត្តាឡីស័កដូចតទៅ៖

- ដឹកនាំ និងសម្របសម្រួលការងារគ្រប់គ្រងសន្តិសុខ និងសណ្តាប់ធ្នាប់

- ត្រួតពិនិត្យ វាយតម្លៃ និងលើកយោបល់អំពីការគ្រប់គ្រងសន្តិសុខ និងសណ្តាប់ធ្នាប់
- សហការជាមួយស្ថាប័នពាក់ព័ន្ធ កសាងផែនការហ្វឹកហ្វឺន និងបំពាក់ដល់កងកម្លាំង និងមន្ត្រីសុខាភិបាលដែលទទួលបន្ទុកការងារគ្រប់គ្រងសន្តិសុខ និងសណ្តាប់ធ្នាប់
- កសាងបទដ្ឋានប្រតិបត្តិការ (SOP) ក្នុងការគ្រប់គ្រងការងារសន្តិសុខ និងសណ្តាប់ធ្នាប់ ដើម្បីស្នើសុំការសម្រេចពីប្រធានគណៈកម្មការអន្តរក្រសួងប្រយុទ្ធនឹងជំងឺកូវីដ-១៩
- ផ្សព្វផ្សាយ ដាក់ឱ្យអនុវត្ត និងតាមដានការអនុវត្តបទដ្ឋានប្រតិបត្តិការ (SOP)
- កសាងផែនការត្រៀមបម្រុងកម្លាំងអន្តរាគមន៍ មន្ត្រីសុខាភិបាល សម្ភារ និងមធ្យោបាយ ដើម្បីធានាដល់ការងារគ្រប់គ្រងសន្តិសុខ និងសណ្តាប់ធ្នាប់
- ក្នុងករណីមានតម្រូវការចាំបាច់ ចាត់តាំងប្រើប្រាស់ និងគ្រប់គ្រងកម្លាំងអន្តរាគមន៍នៅតាមគោលដៅ និងតំបន់ចត្តាឡីស័កដែលបានកំណត់
- សហការជាមួយអាជ្ញាធរមូលដ្ឋាន ស្ថាប័ន និងអង្គភាពពាក់ព័ន្ធក្នុងការអនុវត្តភារកិច្ច
- គ្រប់គ្រងទិន្នន័យអ្នកធ្វើចត្តាឡីស័កនៅតាមគោលដៅ និងតំបន់ចត្តាឡីស័កស្ថិតក្នុងការគ្រប់គ្រង
- កសាងផែនការធានា ផ្គត់ផ្គង់ដល់ដំណើរការគ្រប់គ្រងសន្តិសុខ និងសណ្តាប់ធ្នាប់
- បូកសរុបរបាយការណ៍ប្រចាំថ្ងៃ ស្តីពីលទ្ធផល និងសកម្មភាពការងារសន្តិសុខ និងសណ្តាប់ធ្នាប់នៅតាមគោលដៅ និងតំបន់ចត្តាឡីស័កក្នុងអំឡុងពេលប្រតិបត្តិការ
- បំពេញភារកិច្ចផ្សេងៗ តាមការប្រគល់ជូនពីប្រធានគណៈកម្មការអន្តរក្រសួងដើម្បីប្រយុទ្ធនឹងជំងឺកូវីដ-១៩។

**ប្រការ៣._**

អនុគណៈកម្មការនេះ អាចប្រើប្រាស់មន្ត្រីក្រោមឱវាទក្រសួង-ស្ថាប័នពាក់ព័ន្ធដើម្បីអនុវត្តភារកិច្ច។

គ្រប់ក្រសួង-ស្ថាប័ន និងអាជ្ញាធរពាក់ព័ន្ធត្រូវផ្តល់កិច្ចសហការដល់អនុគណៈកម្មការនេះ ក្នុងការបំពេញភារកិច្ចតាមការចាំបាច់។

**ប្រការ៤._**

អនុគណៈកម្មការនេះ មានលេខាធិការដ្ឋានមួយដែលសមាសភាពត្រូវសម្រេចដោយប្រធានអនុគណៈកម្មការ ដើម្បីប្រមូលព័ត៌មាននិងបូកសរុបរបាយការណ៍ប្រចាំថ្ងៃជូនថ្នាក់ដឹកនាំ ព្រមទាំងសម្របសម្រួលកិច្ចប្រតិបត្តិការផ្សេងៗ។ លេខាធិការដ្ឋាន ត្រូវរៀបចំរបាយការណ៍សរុបជាប្រចាំដាក់ជូនប្រធានគណៈកម្មការអន្តរក្រសួងដើម្បីប្រយុទ្ធនឹងជំងឺកូវីដ-១៩។

**ប្រការ៥._**

សមាសភាពដូចមានចែងក្នុងប្រការ១ ត្រូវចូលរួមកិច្ចប្រជុំតាមការអញ្ជើញរបស់ប្រធាន ឬចាត់តាំងតំណាងដែលមានសិទ្ធិសម្រេច ដើម្បីចូលរួមជំនួសក្នុងករណីអវត្តមាន។ ក្នុងករណីប្រធានអវត្តមាន អនុប្រធានអាចកោះអញ្ជើញ និងដឹកនាំការប្រជុំតាមការប្រគល់សិទ្ធិរបស់ប្រធាន។

អនុគណៈកម្មការនេះ មានសិទ្ធិប្រើប្រាស់ត្រារបស់ក្រសួងសុខាភិបាល សម្រាប់ដំណើរការការងាររបស់ខ្លួន។

**ប្រការ៦._**

ប្រធានអនុគណៈកម្មការ មានសិទ្ធិបង្កើតក្រុមការងារតាមការចាំបាច់។

**ប្រការ៧._**

អនុគណៈកម្មការនេះ អាចស្នើសុំកិច្ចសម្របសម្រួល និងសហប្រតិបត្តិការពីគ្រប់ក្រសួង-ស្ថាប័នពាក់ព័ន្ធរបស់រាជរដ្ឋាភិបាល អាជ្ញាធរដែនដីគ្រប់លំដាប់ថ្នាក់ និងផ្នែកឯកជន នៅក្នុងការបំពេញការងាររបស់ខ្លួន។

**ប្រការ៨._**

តួនាទី និងភារកិច្ចរបស់អនុគណៈកម្មការនេះ ត្រូវមានសុពលភាពរហូតដល់ការប្រយុទ្ធប្រឆាំងនឹងជំងឺកូវីដ-១៩ ត្រូវបានបញ្ចប់ជាស្ថាពរ។

**ប្រការ៩._**

សមាសភាពអនុគណៈកម្មការទាំងអស់ ដែលមាននាមចែងក្នុងប្រការ១ ត្រូវទទួលបន្ទុកអនុវត្តសេចក្តីសម្រេចនេះ ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

ថ្ងៃសុក្រ ១៥កើត ខែផល្គុន ឆ្នាំជូត ទោស័ក ព.ស ២៥៦៤

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី២៦ ខែកុម្ភៈ ឆ្នាំ២០២១

**ម៉ម_ប៊ុនហេង**

**កន្លែងទទួល**

-ទីស្តីការគណៈរដ្ឋមន្ត្រី
-ខុទ្ទកាល័យសម្តេចអគ្គមហាសេនាបតីតេជោនាយករដ្ឋមន្ត្រី
-ក្រសួងមុខងារសាធារណៈ
-ក្រសួង ស្ថាប័នពាក់ព័ន្ធ
-ដូចប្រការ ៩
-ឯកសារ-កាលប្បវត្តិ